គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
**លេខាធិការដ្ឋាន**
លេខៈ ៦៨៥ ស.ល.ក / គ.ជ.អ.ប

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែកក្កដា ឆ្នាំ២០១៦

**សូមគោរពជូន**
**សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
**និងជាប្រធាន គ.ជ.អ.ប**

**កម្មវត្ថុៈ** របាយការណ៍ស្តីពីការធ្វើវិសោធនកម្មច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីជលផល និងច្បាប់ស្តីពីតំបន់ការពារធម្មជាតិ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទសូមគោរពជម្រាបជូន **សម្តេចក្រឡាហោម** មេត្តាជ្រាបថា អនុលោមគោលការណ៍ណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចក្រឡាហោម** នៅក្នុងកិច្ចប្រជុំថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ នាថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១៦ លេខាធិការដ្ឋាន គ.ជ.អ.ប បានសហការជាមួយក្រសួងបរិស្ថាន (ដោយពុំទាន់បានអញ្ជើញតំណាងក្រសួងកសិកម្មឱ្យចូលរួមនៅឡើយទេ) និងតំណាងរដ្ឋបាលថ្នាក់ក្រោមជាតិមួយចំនួនក្នុងការរៀបចំកិច្ចប្រជុំកម្រិតមន្ត្រីបច្ចេកទេសចំនួន២លើក ដើម្បីពិនិត្យពិភាក្សាលម្អិតទៅលើលទ្ធភាពក្នុងការធ្វើវិសោធនកម្មច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីជលផល និងច្បាប់ស្តីពីតំបន់ការពារធម្មជាតិក្នុងគោលបំណងពង្រឹងប្រព័ន្ធ និងរចនាសម្ព័ន្ធនៃការគ្រប់គ្រងធនធានធម្មជាតិទាំងនេះឱ្យកាន់តែមានប្រសិទ្ធភាព។

ជារួម នៅក្នុងកិច្ចប្រជុំទាំង២លើកនេះ ក្រុមការងារបានផ្តោតការយកចិត្តទុកដាក់ទាំងទៅលើការបែងចែកសមត្ថកិច្ចទទួលខុសត្រូវរវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន ព្រមទាំងការបែងចែកសមត្ថកិច្ចទទួលខុសត្រូវរវាងថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធទៅនឹងការគ្រប់គ្រងធនធានធម្មជាតិទាំងនេះ។ ក្រុមការងារបានពិនិត្យ ពិភាក្សាលម្អិតតាមមាត្រានីមួយៗនៃច្បាប់ទាំង៣ និងបានរៀបចំជាសេចក្តីព្រាងបឋមនៃសេចក្តីព្រាងវិសោធនកម្មច្បាប់ស្តីពីព្រៃឈើរួចរាល់ផងដែរ។ ផ្អែកលើការពិនិត្យ ពិភាក្សាក្នុងកិច្ចប្រជុំទាំង២លើកនេះ ក្រុមការងារបានកត់សម្គាល់នូវបញ្ហាសំខាន់ៗមួយចំនួនដែលទាមទារឱ្យមានការសម្រេចចិត្តផ្នែកនយោបាយ។ អាស្រ័យហេតុនេះ លេខាធិការដ្ឋាន គ.ជ.អ.ប សូមគោរពរាយការណ៍ជូន **សម្តេចក្រឡាហោម** អំពីបញ្ហាសំខាន់ៗទាំងនោះដូចខាងក្រោម៖

## I. ការបែងចែកសមត្ថកិច្ចរវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថានលើការគ្រប់គ្រងព្រៃឈើ ជលផល និងតំបន់ការពារធម្មជាតិ

ច្បាប់ស្តីពីព្រៃឈើ និងច្បាប់ស្តីពីជលផលបច្ចុប្បន្នបានផ្តល់សមត្ថកិច្ចគ្រប់គ្រងព្រៃឈើ និងជលផលគ្រប់ប្រភេទឱ្យទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ច្បាប់ទាំង២នេះបានតម្រូវឱ្យបង្កើតរដ្ឋបាលព្រៃឈើ និងរដ្ឋបាលជលផលជាអាជ្ញាធររដ្ឋាភិបាលចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមានតួនាទីជាប្រតិបត្តិករផ្ទាល់ក្នុងការគ្រប់គ្រងព្រៃឈើ និងជលផលនៅទូទាំងប្រទេសកម្ពុជា។

ដោយឡែក ច្បាប់ស្តីពីតំបន់ការពារធម្មជាតិបច្ចុប្បន្នបានផ្តល់សមត្ថកិច្ចគ្រប់គ្រង អភិរក្ស និង អភិវឌ្ឍតំបន់ការពារធម្មជាតិគ្រប់ប្រភេទឱ្យទៅក្រសួងបរិស្ថាន ព្រមទាំងបានតម្រូវឱ្យបង្កើតរដ្ឋបាលការពារ និងអភិរក្សធម្មជាតិធ្វើជាសេនាធិការឱ្យក្រសួងបរិស្ថានក្នុងការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍតំបន់ការពារ ធម្មជាតិទាំងនោះ។

នាពេលថ្មីៗនេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវអនុក្រឹត្យលេខ៣៤ អនក្របក ចុះថ្ងៃទី០៤ ខែ មីនា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលតួនាទី និងភារកិច្ចរបស់ក្រសួងបរិស្ថាន និងរបស់ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទពាក់ព័ន្ធនឹងសមត្ថកិច្ច និងការគ្រប់គ្រងតំបន់វិនិយោគអភិវឌ្ឍន៍សម្បទានដីសេដ្ឋកិច្ច និងការគ្រប់គ្រងតំបន់ការពារ និងអភិរក្សព្រៃឈើ និងជលផល ដោយតម្រូវឱ្យផ្ទេរតំបន់វិនិយោគអភិវឌ្ឍន៍ សម្បទានដីសេដ្ឋកិច្ចទាំងអស់ដែលស្ថិតក្រោមសមត្ថកិច្ច និងការគ្រប់គ្រងរបស់ក្រសួងបរិស្ថានឱ្យទៅស្ថិត ក្រោមសមត្ថកិច្ច និងការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងត្រូវផ្ទេរតំបន់ការពារ និងអភិរក្សព្រៃឈើ និងជលផលទាំងអស់ដែលស្ថិតក្រោមសមត្ថកិច្ច និងការគ្រប់គ្រងរបស់ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទឱ្យទៅស្ថិតក្រោមសមត្ថកិច្ច និងការគ្រប់គ្រងរបស់ក្រសួងបរិស្ថាន។

យោងតាមអនុក្រឹត្យនេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានផ្ទេរព្រៃការពារ និងតំបន់ អភិរក្សព្រៃឈើ និងតំបន់ព្រៃផ្តល់ផលមួយចំនួនដែលកន្លងមកស្ថិតក្រោមការគ្រប់គ្រងរបស់ខ្លួន (ថ្មីៗកន្លង មកនេះ រាជរដ្ឋាភិបាលបានសម្រេចដាក់ជាតំបន់ទាំងនេះជាព្រៃការពារ និងតំបន់អភិរក្ស) សរុបចំនួន ជាង**២លានហិកតា**ទៅឱ្យស្ថិតក្រោមសមត្ថកិច្ចគ្រប់គ្រងរបស់ក្រសួងបរិស្ថានវិញ បន្ថែមលើតំបន់ការពារ ធម្មជាតិដែលក្រសួងបរិស្ថានកំពុងគ្រប់គ្រងប្រមាណជាង**៣លានហិកតា**។ ប្រការនេះ បានធ្វើឱ្យក្រសួង បរិស្ថានមានសមត្ថកិច្ចគ្រប់គ្រងតំបន់ការពារធម្មជាតិនាពេលបច្ចុប្បន្នរហូតដល់ចំនួន**ជិត៦លានហិកតា**។

តាមការជាក់ស្តែង ផ្ទៃដីតំបន់ការពារធម្មជាតិជិត**៦លានហិកតា**ខាងលើនេះ បានគ្របដណ្តប់ទៅ លើតំបន់ព្រៃឈើសំខាន់ៗដែលនៅសេសសល់**ស្ទើរតែទាំងស្រុង**នៅទូទាំងប្រទេស។

ដោយឡែក ផ្អែកតាមច្បាប់ និងអនុក្រឹត្យខាងលើ ការគ្រប់គ្រងព្រៃឈើ និងជលផលនៅតែស្ថិត នៅក្រោមសមត្ថកិច្ចរបស់ក្រសួងទាំងពីរ។ មានន័យថា ការគ្រប់គ្រងព្រៃឈើ និងជលផល**<u>នៅក្នុង</u>**តំបន់ ការពារធម្មជាតិត្រូវស្ថិតក្រោមសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន និងការគ្រប់គ្រងព្រៃឈើ និងជលផល**<u>នៅ ក្រៅ</u>**តំបន់ការពារធម្មជាតិត្រូវស្ថិតក្រោមសមត្ថកិច្ចរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ពាក់ព័ន្ធនឹងស្ថានភាពនេះ មានជម្រើសសំខាន់ៗ**ចំនួន៣**ដែលគួរពិចារណាក្នុងការធ្វើវិសោធនកម្ម ច្បាប់ទាំង៣ខាងលើ គឺ៖

- **ជម្រើសទី១៖** ផ្តល់សមត្ថកិច្ចគ្រប់គ្រងទាំងបរិស្ថាន និងព្រៃឈើ**<u>ទាំងនៅក្នុង និងនៅក្រៅ</u>**តំបន់ ការពារធម្មជាតិឱ្យទៅក្រសួងបរិស្ថាន ដោយរក្សាទុកសមត្ថកិច្ចគ្រប់គ្រងជលផលនៅក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទដដែល។ ជម្រើសនេះ គប្បីបញ្ចូលច្បាប់ស្តីពីការគ្រប់គ្រងតំបន់ ការពារធម្មជាតិ និងច្បាប់ស្តីពីព្រៃឈើឱ្យទៅជាច្បាប់តែមួយ ហើយរក្សាច្បាប់ជលផលឱ្យនៅជា ច្បាប់ដោយឡែកដដែល ដោយគ្រាន់តែធ្វើវិសោធនកម្មលើជំពូក និងមាត្រាមួយចំនួនដើម្បីធានា ដល់ការបែងចែកសមត្ថកិច្ច និងការទទួលខុសត្រូវរវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។ ជម្រើសនេះ ជាជម្រើសដែលលេខាធិការដ្ឋាន គ.ជ.អ.ប យល់ថា

មានលក្ខណៈសមស្របទៅនឹងការសម្រេចចិត្តរបស់រាជរដ្ឋាភិបាលក្នុងការផ្ទេរព្រៃការពារ និងតំបន់អភិរក្សព្រៃឈើ ព្រមទាំងតំបន់ព្រៃផ្តល់ផលមួយចំនួនឱ្យទៅក្រសួងបរិស្ថាន ដោយហេតុថា ផ្ទៃដីតំបន់ការពារធម្មជាតិជិត**៦លានហិកតា** ដែលស្ថិតក្រោមសមត្ថកិច្ចគ្រប់គ្រងរបស់ក្រសួងបរិស្ថាននាពេលបច្ចុប្បន្ននេះ បានគ្របដណ្តប់ទៅលើតំបន់ព្រៃឈើសំខាន់ៗដែលនៅសេសសល់ស្ទើរតែទាំងស្រុងនៅទូទាំងប្រទេសទៅហើយ។ ជម្រើសនេះ ក៏មានការគាំទ្រពីក្រសួងបរិស្ថានផងដែរ។

- **ជម្រើសទី២៖** ផ្តល់សមត្ថកិច្ចគ្រប់គ្រងបរិស្ថាន ព្រៃឈើ និងជលផលទាំងនៅក្នុង និងនៅក្រៅតំបន់ការពារធម្មជាតិទាំងអស់ឱ្យទៅក្រសួងបរិស្ថាន ដោយទុកឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមានសមត្ថកិច្ចទទួលខុសត្រូវតែទៅលើការលើកកម្ពស់ផលិតភាពកសិកម្ម រួមមានដូចជាការពង្រឹងប្រសិទ្ធភាព និងផលិតភាពនៃការដាំដំណាំកសិកម្ម ការដាំដំណាំកសិ-ឧស្សាហកម្ម ការចិញ្ចឹមសត្វ និងវារីវប្បកម្មជាលក្ខណៈគ្រួសារ អាជីវកម្ម សិប្បកម្ម និងឧស្សាហកម្មជាដើម។ ជាមួយគ្នានេះដែរ ជម្រើសនេះក៏នឹងជំរុញឱ្យក្រសួងបរិស្ថានពង្រឹងការទទួលខុសត្រូវ និងមានគណនេយ្យភាពច្បាស់លាស់លើការគ្រប់គ្រង ការអភិវឌ្ឍ និងការអភិរក្សធនធានធម្មជាតិទាំងអស់។ ក្នុងករណីនេះ គប្បីដាក់បញ្ចូលច្បាប់ទាំង៣នេះឱ្យទៅជាច្បាប់តែមួយ ដែលអាចឱ្យឈ្មោះថា **ច្បាប់ស្តីពីការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន**។ ជាមួយគ្នានេះដែរ ក្រសួងទាំង២ក៏គប្បីត្រូវបានប្តូរឈ្មោះថា ជា**ក្រសួងគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន** និង**ក្រសួងកសិកម្ម**។
- **ជម្រើសទី៣៖** ការគ្រប់គ្រងព្រៃឈើ ជលផល និងតំបន់ការពារធម្មជាតិត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់ក្រសួងទាំង២ដូចស្ថានភាពបច្ចុប្បន្ននេះ គឺក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមានសមត្ថកិច្ចគ្រប់គ្រងព្រៃឈើ និងជលផល**នៅក្រៅ**តំបន់ការពារធម្មជាតិ ហើយក្រសួងបរិស្ថានមានសមត្ថកិច្ចគ្រប់គ្រងព្រៃឈើ និងជលផល**នៅក្នុង**តំបន់ការពារធម្មជាតិ។ ជម្រើសនេះនឹងតម្រូវឱ្យមានការកំណត់ឡើងវិញនូវព្រំប្រទល់ព្រៃឈើ និងតំបន់គ្រប់គ្រងជលផលដែល**នៅក្រៅ** និង**នៅក្នុង**តំបន់ការពារនិងអភិរក្ស ដើម្បីកំណត់ឱ្យបានច្បាស់អំពីតំបន់ព្រៃឈើ និងតំបន់ជលផលណាខ្លះដែលត្រូវស្ថិតក្រោមសមត្ថកិច្ចរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រោមសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន។ ជម្រើសនេះ ក្រសួងទាំង២មានតួនាទីភារកិច្ចប្រហាក់ប្រហែលគ្នា ក៏ប៉ុន្តែគ្រប់គ្រងនៅក្នុងតំបន់ផ្សេងគ្នា ដែលប្រការនេះតម្រូវឱ្យក្រសួងទាំង២ត្រូវមានរចនាសម្ព័ន្ធស្ថាប័ន និងមន្ត្រីអនុវត្តច្បាប់លើវិស័យព្រៃឈើ និងជលផលដូចគ្នា។ ជម្រើសនេះ ក៏ជាមានលទ្ធភាពក្នុងការដាក់បញ្ចូលច្បាប់ទាំង៣ឱ្យទៅជាច្បាប់តែមួយបានផងដែរ។

## II. ការបែងចែកសមត្ថកិច្ចរវាងក្រសួង ស្ថាប័នថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិលើការគ្រប់គ្រងព្រៃឈើ ជលផល និងតំបន់ការពារធម្មជាតិ

ច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីជលផល និងច្បាប់ស្តីពីតំបន់ការពារធម្មជាតិបានផ្តល់សិទ្ធិផ្តាច់មុខទៅឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថានក្នុងការគ្រប់គ្រង អភិវឌ្ឍ និងអភិរក្សព្រៃឈើ ជលផល និងតំបន់ការពារធម្មជាតិ តាមរយៈអង្គភាពខ្សែបណ្តោយរបស់ខ្លួន។ ច្បាប់ទាំង៣នេះ

បានផ្តល់តួនាទីឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ និងស្ថាប័នដទៃទៀតត្រឹមតែផ្តល់កិច្ចសហការក្នុងការទប់ស្កាត់បទល្មើសព្រៃឈើ បទល្មើសនេសាទ និងបទល្មើសក្នុងតំបន់ការពារធម្មជាតិផ្អែកតាមការស្នើសុំរបស់រដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល និងរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ។ ច្បាប់ទាំង៣នេះពុំបានផ្តល់សិទ្ធិអំណាចដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការចូលរួមចំណែកគ្រប់គ្រង ថែរក្សាការពារ និងអភិរក្សធនធានព្រៃឈើ ជលផល និងតំបន់ការពារធម្មជាតិដែលស្ថិតនៅក្នុងដែនដីរបស់ខ្លួនឡើយ។ ការផ្តល់សិទ្ធិផ្តាច់មុខឱ្យទៅក្រសួងទាំង២ និងការពុំបានផ្តល់សិទ្ធិអំណាចសមស្របឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិបានធ្វើឱ្យការចាត់វិធានការទប់ស្កាត់បទល្មើសព្រៃឈើ ជលផល និងតំបន់ការពារធម្មជាតិពុំសូវមានប្រសិទ្ធភាព ហើយជាទូទៅ ត្រូវបានស្ថិតនៅក្នុងស្ថានភាពឆ្លើយដាក់គ្នាទៅវិញទៅមករវាងរដ្ឋបាលមានសមត្ថកិច្ច (រដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល រដ្ឋបាលការពារ និងអភិរក្សធម្មជាតិ) និងរដ្ឋបាលថ្នាក់ក្រោមជាតិ (អាជ្ញាធរមូលដ្ឋាន) និងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធផ្សេងទៀត (កងរាជអាវុធហត្ថ និងកងកម្លាំងប្រដាប់អាវុធដទៃទៀត)។

នាពេលកន្លងមក ទោះបី រាជរដ្ឋាភិបាលបានដាក់ចេញនូវបទបញ្ញានានាដើម្បីជំរុញឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ និងអង្គភាពពាក់ព័ន្ធដទៃទៀតចូលរួមទទួលខុសត្រូវលើការគ្រប់គ្រង និងអភិវឌ្ឍធនធានព្រៃឈើ ជលផល និងតំបន់ការពារធម្មជាតិតាមរយៈការពង្រឹងយន្តការគណៈបញ្ជាការឯកភាពនៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌក៏ដោយ ក៏កិច្ចការទាំងនេះ គឺជាវិធានការសម្រាប់ដោះស្រាយបញ្ហាបន្ទាន់ចំពោះមុខក្នុងរយៈពេលខ្លីតែប៉ុណ្ណោះ។

ដើម្បីធានាដល់ការពង្រឹងការគ្រប់គ្រង និងការអភិវឌ្ឍធនធានព្រៃឈើ ជលផល និងតំបន់ការពារធម្មជាតិប្រកបដោយនិរន្តរភាពសម្រាប់រយៈពេលវែង និងស្របតាមការវិវត្តនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការដែលកំពុងផ្តោតទៅលើការផ្ទេរសិទ្ធិអំណាច ផ្ទេរមុខងារ និងផ្ទេរធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ការធ្វើវិសោធនកម្មច្បាប់ទាំង៣នេះ ក៏ចាំបាច់ត្រូវផ្តោតជាសំខាន់ទៅលើការបែងចែកឡើងវិញនូវសមត្ថកិច្ចរវាងក្រសួង ស្ថាប័នមានសមត្ថកិច្ចនៅថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាដល់ការប្រគល់សិទ្ធិអំណាច មុខងារ តួនាទីភារកិច្ច ការទទួលខុសត្រូវ និងធនធានសមស្របទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រង ការអភិវឌ្ឍ និងការអភិរក្សធនធានធម្មជាតិនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ពាក់ព័ន្ធនឹងបញ្ហានេះ ការបែងចែកឡើងវិញនូវសមត្ថកិច្ចរវាងក្រសួង ស្ថាប័នមានសមត្ថកិច្ចនៅថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ គួរកំណត់ដូចខាងក្រោម៖

- **ក្រសួង ស្ថាប័នមានសមត្ថកិច្ចនៅថ្នាក់ជាតិ** (ក្រសួងបរិស្ថាន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាស្រ័យទៅតាមការសម្រេចចិត្តលើជម្រើសខាងលើ)៖ មានតួនាទីដឹកនាំ និងផ្តល់គោលការណ៍តម្រង់ទិស ដើម្បីធានាដល់ការគ្រប់គ្រង និងការអភិវឌ្ឍន៍ព្រៃឈើ ជលផល និងតំបន់ការពារធម្មជាតិប្រកបដោយនិរន្តរភាព។ តាមន័យនេះ ក្រសួង ស្ថាប័នមានសមត្ថកិច្ចនៅថ្នាក់ជាតិមានភារកិច្ច និងការទទួលខុសត្រូវទៅលើការរៀបចំគោលនយោបាយជាតិ ផែនការយុទ្ធសាស្ត្រជាតិ ផែនការប្រើប្រាស់ដីធ្លីជាតិ បទដ្ឋានបច្ចេកទេស អធិការកិច្ច ការអភិវឌ្ឍសមត្ថភាព និងការសម្រេចលើកិច្ចការធំៗមួយចំនួនផ្សេងទៀត ដូចជា ការកំណត់តំបន់ ប្រភេទ ព្រំប្រទល់ និងផែនទីព្រៃឈើ និងតំបន់គ្រប់គ្រងជលផល ការចុះបញ្ជិកាទ្រព្យសម្បត្តិធនធានធម្មជាតិ ការ

កំណត់កូតាប្រមូលផល និងកូតានាំចេញនាំចូល ការនាំចេញនាំចូលផល អនុផលព្រៃឈើ និងជលផលជាដើម។

- **រដ្ឋបាលថ្នាក់ក្រោមជាតិ៖** មានតួនាទី និងការទទួលខុសត្រូវលើការគ្រប់គ្រង ការថែរក្សាការពារ ការអភិវឌ្ឍ និងការអភិរក្សព្រៃឈើ ជលផល និងតំបន់ការពារធនធានធម្មជាតិដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ស្របតាមគោលនយោបាយជាតិ ផែនការយុទ្ធសាស្ត្រជាតិ ផែនការប្រើប្រាស់ដីធ្លីជាតិ និងបទដ្ឋានបច្ចេកទេសដែលបានកំណត់។ ដើម្បីជានាដល់ការអនុវត្តតួនាទី និងការទទួលខុសត្រូវនេះ រដ្ឋបាលថ្នាក់ក្រោមជាតិចាំបាច់ត្រូវមានអង្គភាព និងមន្ត្រីទទួលបន្ទុកការងារព្រៃឈើ ការងារជលផល និងការងារការពារ និងអភិរក្សធម្មជាតិ។ ក្នុងន័យនេះ អង្គភាពរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល និងរដ្ឋបាលការពារនិងអភិរក្សធម្មជាតិដែលជាអង្គភាពខ្សែបណ្តោយក្រោមចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថានដែលកំពុងអនុវត្តតួនាទីជាប្រតិបត្តិករផ្ទាល់ក្នុងការគ្រប់គ្រងព្រៃឈើ ជលផល និងតំបន់ការពារធម្មជាតិ រួមមានដូចជា ខណ្ឌ ផ្នែក សង្កាត់រដ្ឋបាលព្រៃឈើ ខណ្ឌ ផ្នែក សង្កាត់រដ្ឋបាលជលផល ក្រុមអភិរក្សតំបន់ការពារធម្មជាតិ ។ល។ គួរត្រូវបានផ្ទេរចូលទៅក្នុងរចនាសម្ព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធ្វើជាសេនាធិការឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ និងត្រូវមានគណនេយ្យភាពចំពោះរដ្ឋបាលថ្នាក់ក្រោមជាតិសាមីនីមួយៗក្នុងការគ្រប់គ្រង ថែរក្សាការពារនិងអភិរក្សធនធានធម្មជាតិនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ទោះជាយ៉ាងនេះក្តី ក្រសួង ស្ថាប័នមានសមត្ថកិច្ចនៅថ្នាក់ជាតិនៅតែជាស្ថាប័នដែលត្រូវមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាលក្នុងវិស័យព្រៃឈើ ជលផល និងតំបន់ការពារធម្មជាតិ។ ទន្ទឹមគ្នានេះ រដ្ឋបាលថ្នាក់ក្រោមជាតិគឺជាស្ថាប័នដែលត្រូវមានគណនេយ្យភាពចំពោះក្រសួង ស្ថាប័នមានសមត្ថកិច្ចនៅថ្នាក់ជាតិក្នុងការអនុវត្តតាមគោលនយោបាយជាតិ ផែនការយុទ្ធសាស្ត្រជាតិ និងបទដ្ឋានបច្ចេកទេសសម្រាប់ការគ្រប់គ្រង ការថែរក្សាការពារ ការអភិវឌ្ឍ និងការអភិរក្សធនធានធម្មជាតិដែលបានកំណត់ និងត្រូវមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

## III សំណើសុំគោលការណ៍ដឹកនាំលើចំណុចសំខាន់ៗ

ដើម្បីជានាដល់ការរៀបចំសេចក្តីព្រាងច្បាប់វិសោធនកម្មលម្អិតតាមមាត្រានីមួយៗនៃច្បាប់ទាំង៣ខាងលើនេះ លេខាធិការដ្ឋាន គ.ជ.អ.ប សូមគោរពស្នើសុំគោលការណ៍ដឹកនាំលើកិច្ចការសំខាន់ៗមួយចំនួនដូចខាងក្រោម៖

**ទីមួយ៖** ស្នើសុំការសម្រេចលើជម្រើសណាមួយពាក់ព័ន្ធនឹងការបែងចែកសមត្ថកិច្ចឡើងវិញរវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថានដូចបានរៀបរាប់ក្នុងចំណុចទី I ខាងលើ។

**ទីពីរ៖** ស្នើសុំការសម្រេចចិត្តពាក់ព័ន្ធនឹងការបែងចែកសមត្ថកិច្ចឱ្យបានច្បាស់លាស់រវាងក្រសួងមានសមត្ថកិច្ចនៅថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដូចបានរៀបរាប់ក្នុងចំណុចទីIIខាងលើ។

**ទីបី៖** ស្នើសុំរាជរដ្ឋាភិបាលដាក់ចេញនូវ<u>**សារាចរណែនាំជាបន្ទាន់**</u>អំពីវិធានការចំពោះមុខនានា

ជាពិសេសការពង្រឹងសមត្ថកិច្ច និងការទទួលខុសត្រូវរបស់គណៈបញ្ជាការឯកភាពនៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្នុងការចាត់វិធានការជាក់ស្តែងដើម្បីទប់ស្កាត់បទល្មើសព្រៃឈើ ផលជល និងតំបន់ការពារធម្មជាតិក្នុងដែនសមត្ថកិច្ចរបស់ខ្លួនឱ្យមានប្រសិទ្ធភាព ដោយហេតុថា នាពេលបច្ចុប្បន្ននេះកំពុងកើតមាននូវបាតុភាពមិនប្រក្រតីដ៏គួរឱ្យព្រួយបារម្ភ ដែលបង្កឡើងដោយបុគ្គលឆ្លៀតឆក់ឱកាសមួយចំនួននៅតំបន់ដែលកំពុងផ្ទេរសមត្ថកិច្ចគ្រប់គ្រងរវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន។

**ទីបួន៖** ស្នើសុំធ្វើការកែសម្រួលរចនាសម្ព័ន្ធរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល និងរដ្ឋបាលការពារ និងអភិរក្សធម្មជាតិក្នុងក្របខណ្ឌនៃស្ថាប័ននៅថ្នាក់ជាតិ និងនៅថ្នាក់ក្រោមជាតិ ដើម្បីធានាឱ្យមានការបែងចែកតួនាទី និងការទទួលខុសត្រូវយ៉ាងច្បាស់លាស់រវាងស្ថាប័នរៀបចំគោលនយោបាយ (ថ្នាក់ក្រសួង) និងស្ថាប័នអនុវត្តគោលនយោបាយ (រដ្ឋបាលថ្នាក់ក្រោមជាតិ)។

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើ សូម **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប** មេត្តាពិនិត្យ និងផ្តល់គោលការណ៍ណែនាំដ៏ខ្ពង់ខ្ពស់ ដើម្បីជាការតម្រង់ទិសដល់លេខាធិការដ្ឋាន គ.ជ.អ.ប ក្នុងការបន្តកិច្ចដំណើរការធ្វើវិសោធនកម្មច្បាប់ទាំង៣ស្របតាមការសម្រេចចិត្តរបស់រាជរដ្ឋាភិបាល។

សូម **សម្តេចក្រឡាហោម** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ។

**ជ. ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប**